ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រៃវែង

# កម្មវិធី
## សន្និសីទសារព័ត៌មាន ស្តីពីភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រៃវែង

ថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣
**ទីកន្លែង៖** អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី

**ម៉ោង ៧:៣០នាទី :** សមាជិក សមាជិកានៃគណៈប្រតិភូខេត្តព្រៃវែង អញ្ជើញដល់ទីស្តីការគណៈរដ្ឋមន្ត្រី

**៨:០០នាទី :** គណៈប្រតិភូខេត្តព្រៃវែង អញ្ជើញជួបសំណេះសំណាលជាមួយ **ឯកឧត្តម ផៃ ស៊ីផាន ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា** (នៅបន្ទប់លេខ១១១ ជាន់ទី១)

**៩:៣០នាទី :** គណៈប្រតិភូខេត្តព្រៃវែង អញ្ជើញចូលសាលសន្និសីទសារព័ត៌មាន

**ចាប់ផ្តើមកម្មវិធី**

- ប្រសាសន៍បើកសន្និសីទសារព័ត៌មានរបស់ **ឯកឧត្តម ផៃ ស៊ីផាន ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា**
- បទអន្តរាគមន៍ ស្តីពីភាពជោគជ័យក្នុងរយៈពេលកន្លងមក របស់រដ្ឋបាលខេត្តព្រៃវែង របស់ **ឯកឧត្តម ជា សុមេធី អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង**
- បទអន្តរាគមន៍ របស់លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង (**រយៈពេល១០នាទី**)
- បទអន្តរាគមន៍ របស់លោកប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រៃវែង (**រយៈពេល១០នាទី**)
- សំនួររបស់អ្នកសារព័ត៌មាន
- ការឆ្លើយបំភ្លឺរបស់ប្រតិភូខេត្តព្រៃវែង
- ប្រសាសន៍បិទសន្និសីទសារព័ត៌មានរបស់ **ឯកឧត្តម ផៃ ស៊ីផាន ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា**
- ថតរូបអនុស្សាវរីយ៍
- ចប់កម្មវិធី

*សូមរក្សាសិទ្ធកែប្រែកម្មវិធីក្នុងករណីចាំបាច់ !*

ភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ទូរស័ព្ទ និងទូរសារ : (+៨៥៥) ៤៣ ២១៨ ៨៨៨,អ៊ីមែល: preyvengprovince@gmail.com.kh
1Village,Sangkat Kampong Leav,Krong Prey Veng,Prey Veng Province Phone and Fax: (+855) 43 218 888, Email: preyvengprovince@gmail.com.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រៃវែង

## បញ្ជីរាយនាមប្រតិភូខេត្តព្រៃវែង
## ដើម្បីចូលរួមជាវាគ្មិនកិត្តិយសក្នុងសន្និសីទសារព័ត៌មាន
## ស្តីពីភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រៃវែង

ថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

ទីកន្លែង៖ ទីស្តីការគណៈរដ្ឋមន្ត្រី សាលសេរីភាព ជាន់ផ្ទាល់ដី

| ល.រ | គោត្តនាម-នាម | តួនាទី-អង្គភាព | លេខទូរស័ព្ទ |
|---|---|---|---|
| ១ | ឯកឧត្តម **ជា សុមេធី** | អភិបាលនៃគណៈអភិបាលខេត្ត | ០៩៧ ៥៣៣ ៣៣៣៣ |
| ២ | ឯកឧត្តម **សួន សុម៉ាលីន** | អភិបាលរងនៃគណៈអភិបាលខេត្ត | ០៩៧ ៨៨៨៨ ៧៦៦ |
| ៣ | ឯកឧត្តម **ចាន់ វ៉ាន់** | អភិបាលរងនៃគណៈអភិបាលខេត្ត | ០៩៧ ៧៦៩ ៤៩០៨ |
| ៤ | ឯកឧត្តម **អន តារៈ** | អភិបាលរងនៃគណៈអភិបាលខេត្ត | ០៨៨ ៥៨៨ ៨៨៦៦ |
| ៥ | លោក **ឡាច គីវ៉ាត់** | នាយករដ្ឋបាលសាលាខេត្ត | ០៩៧ ៧៧៧ ៨៩៤៩ |
| ៦ | លោកឧ.ទោ **ឈឿន ម៉ិនធន** | ស្នងការនគរបាលខេត្ត | ០៨៨ ៦៦៦៦ ៧៩ |
| ៧ | លោកឧ.ត្រី **ឈួន គឹមសាន** | មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | ០៩៧ ៧៧៧៧ ៧៧៣ |
| ៨ | លោក **សេង បញ្ញាឫទ្ធិ** | ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត | ០៩៧ ២៧ ៨៤ ៧៧៧ |
| ៩ | លោក **អ៊ុក សំណាង** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | ០៨៨ ៨៨ ៣៤០១៦ |
| ១០ | លោក **ប៉ាវ សុធីរ** | ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ០៩៩ ២៦៦ ៣៦៦ |
| ១១ | លោក **អ៊ុន សុធា** | ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត | ០៨៨ ២៤៤ ៣៣៣៣ |
| ១២ | លោក **ឡុក ចុឌ្ឍី** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | ០១២ ៩៨ ៩៥ ៦៧ |
| ១៣ | លោក **ជា ភក្កដា** | ប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | ០១១ ៧៤៦ ៧៩១ |
| ១៤ | លោក **ញ៉ែម សៅត្រី** | ប្រធានមន្ទីរព័ត៌មានខេត្ត | ០៩៧ ៩២២ ២១ ៦៤ |
| ១៥ | លោក **ឃុន សាឿន** | ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | ០១២ ៩៥៥ ៩៥៨ |
| ១៦ | លោក **អេង ផេងអាន** | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ០៧៧ ៩៧៩ ៧៥២ |
| ១៧ | លោក **តូច ទ៉ារដ្ឋា** | ប្រធានមន្ទីរបរិស្ថានខេត្ត | ០១២ ៤៧៥៧៥៥ |
| ១៨ | លោក **ហ៊ុន ណោត** | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទាខេត្ត | ០១៧ ៥២៧ ៥៧៩ |
| ១៩ | លោក **សរ បូរីរក្ស** | នាយករងរដ្ឋបាល សាលាខេត្ត | ០៣១ ៧៩៧ ៦៦៦៦ |
| ២០ | លោក **ទ៉ា សុធា** | ប្រធានអង្គភាពច្រកចេញចូលតែមួយខេត្ត | ០៩៧ ៨៤៨ ៨៨២៧ |

ថ្ងៃ សុក្រ ១១ រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ព្រៃវែង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២៣

**អភិបាលខេត្ត**

ជា សុមេធី

**បញ្ជាក់:**

សម្លៀកបំពាក់: - មន្ត្រីរាជការស៊ីវិល៖ អាវធំ-ក្រវ៉ាត់ក

- កងកម្លាំង៖ ឯកសណ្ឋានស័ក្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រៃវែង**

# សន្និសីទសារព័ត៌មាន
## ស្តីពីភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តព្រៃវែង
## ដោយ ឯកឧត្តម ជា សុមេធី អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

ថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣
**ទីកន្លែង៖** ទីស្តីការគណៈរដ្ឋមន្ត្រី អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

- ជាបឋម ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ **សម្តេចព្រះមហាសង្ឃរាជទាំង២គណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ** ជាទីគោរពសក្ការៈ!
- សូមគោរព **សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់** ដែលមានវត្តមាននៅក្នុងសន្និសីទសារព័ត៌មាន និងកំពុងទស្សនាការផ្សាយផ្ទាល់នាឱកាសនេះ!

ថ្ងៃនេះ ក្នុងនាមរដ្ឋបាលខេត្តព្រៃវែង ខ្ញុំបាទពិតជាមានក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មាន **ស្តីពីភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តព្រៃវែង** និងសូមថ្លែងអំណរគុណដល់បងប្អូនអ្នកសារព័ត៌មាននៅទីនេះ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋ ដែលកំពុងតាមដានសន្និសីទសារព័ត៌មាន នាឱកាសនេះផងដែរ ។

ឆ្លៀតក្នុងឱកាសដ៏សែនវិសេសវិសាលនេះ ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងខេត្ត សូម **អរគុណសន្តិភាព** អរគុណថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ដែលបានកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ ក្នុងសុខសន្តិភាពដ៏ប្រសើរក្រៃលែង។ គុណូបការៈ និងសមិទ្ធផលទាំងអស់នេះហើយ ដែលប្រជាជនកម្ពុជាទទួលបានដោយពេញលេញ និងកំពុងអភិវឌ្ឍន៍ទៅមុខដោយភាពស្វាហាប់។

ក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជានាយករដ្ឋមន្ត្រី** និងការជួយឧបត្ថម្ភគាំទ្រពីក្រសួង ស្ថាប័នថ្នាក់ជាតិ ជាពិសេស ក្រោមការចង្អុលណែនាំផ្ទាល់ពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រៃវែង** រដ្ឋបាលខេត្តបានខិតខំប្រមូលផ្តុំ គំនិតស្មារតីដឹកនាំអភិវឌ្ឍន៍ខេត្តឲ្យមានរីកចម្រើនជាបន្តបន្ទាប់ និងសម្រេចបានសមិទ្ធផលប្រកបដោយមោទនៈភាពក្នុងរយៈពេល**៥ឆ្នាំ**(**២០១៨-២០២២**)ចុងក្រោយនេះ រួមមានដូចតទៅ៖

## I-អំពីស្ថានភាពទូទៅ

### ក.ស្ថានភាពភូមិសាស្ត្រ

- ខេត្តព្រៃវែងស្ថិតនៅប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា ទីរួមខេត្តមានចំងាយ ៩៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងចម្ងាយ១០០គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៨

- ខេត្តមានស្រុកចំនួន១២ និងក្រុងចំនួន១ រួមមានឃុំចំនួន១១២ និងសង្កាត់ចំនួន៤ មានភូមិចំនួន**១.១៦៨** និងមានផ្ទៃដីសរុប **៤.៨៨៣គម²** ។
- ខេត្តមានខ្សែបន្ទាត់ព្រំដែនកម្ពុជា-វៀតណាម ប្រវែង ៨៤,២គីឡូម៉ែត្រ។
- ប្រជាពលរដ្ឋក្នុងខេត្ត សរុបចំនួន២៩៥.០៧៤គ្រួសារ ស្មើនឹងមនុស្ស ចំនួន១.២៦៣.១៨២នាក់ ស្រី ៦៥២.៨៧៩នាក់ ក្នុងនោះប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើង ចំនួន៨១០.០៩១នាក់, ស្រី ៤២៤.៩៦១នាក់។
- បច្ចុប្បន្ន ខេត្តព្រៃវែងមានមន្ត្រីរាជការសរុបចំនួន ១១.១៣៤នាក់ ក្នុងនោះមន្ត្រីរាជការក្របខណ្ឌ(ក) ចំនួន ១.៩៣៣នាក់,ក្របខណ្ឌ(ខ)ចំនួន៤.១១១នាក់ និងមន្ត្រីរាជការក្របខណ្ឌ(គ)ចំនួន៥.០៩០នាក់។

**ខ.ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ**

- ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងដែនសមត្ថកិច្ចរបស់ខេត្ត ត្រូវបានរក្សាការពារបានយ៉ាងល្អប្រសើរ ជាក់ស្តែងក្នុងឆ្នាំ២០២២ លើការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ខេត្តព្រៃវែង ក្នុងចំណោម១១៦ឃុំ-សង្កាត់ ទទួលបានជ័យលាភីលេខ១ ចំនួន៨៥ឃុំ-សង្កាត់ លេខ២ ចំនួន២៩ឃុំ និងលេខ៣ ចំនួន២ឃុំ។

## II-សមិទ្ធផលសំខាន់ៗសម្រេចបាន រយៈពេល៥ឆ្នាំ

### ក-ការងារគ្រប់គ្រងការរីករាលដាលជំងឺកូវីដ-១៩ ក្នុងខេត្ត

ខេត្តព្រៃវែងមានអ្នកវិជ្ជមាន១១.២៤៨នាក់ បានព្យាបាលជាសះស្បើយ ១០.៩២១នាក់ និងស្លាប់ ៣២៧នាក់។ ក្នុងនោះបានឧបត្ថម្ភដល់ក្រុមគ្រួសារអ្នកស្លាប់ទទួលបានថវិកាគោលនយោបាយរាជរដ្ឋាភិបាល ក្នុងម្នាក់ ២លានរៀល និងសម្រាប់ការបូជាសព **ចំណាយសរុបថវិកា ៨៧៩លានរៀល**។

ចំពោះអ្នកធ្វើចត្តាឡីស័ក និងក្រុមការងារតាមមណ្ឌលចត្តាឡីស័ក ក្នុងអំឡុងវិធានការសុខាភិបាល ទទួលបានការឧបត្ថម្ភក្នុងម្នាក់ថវិកា២ម៉ឺនរៀលក្នុង១ថ្ងៃ**សរុបថវិកា ៥.៧៦៩(ប្រាំបីលានប្រាំពីររយហុកសិបប្រាំបួនលានរៀល)**។

គិតមកដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ ខេត្តព្រៃវែងសម្រេចបាននូវការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋក្នុងខេត្ត សរុបបានចំនួន **១.១០៦.៧១១នាក់ ស្មើនឹង៩៦,៣០%នៃផែនការ១.១៤៩.២៤០នាក់ ក្នុងនោះដូសទី២ចំនួន ៧១៣.៩៣៤នាក់, ដូសទី៣ចំនួន ៦២០.៩៤០នាក់, ដូសទី៤ចំនួន ៣៤៨.៦៨២នាក់, ដូសទី៥ចំនួន ២២១.៧៦២នាក់ និងដូសទី៦ចំនួន៣៩.៣៩២នាក់**។

### ខ-ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងខេត្តព្រៃវែង

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដឹកនាំប្រទេសជាតិពុះពារជំនះនូវវិបត្តិ និងបញ្ហាប្រឈមនានាជាសកល ដែលបាននិងកំពុងមានវិបត្តិប្រែប្រួលដ៏ស្មុគស្មាញបំផុតប្រកបដោយជោគជ័យ ដោយខិតខំស្តារ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ស្ទុះងើបឡើងវិញយ៉ាងឆាប់រហ័ស។ ជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ពីសុខទុក្ខប្រជាពលរដ្ឋរងគ្រោះ ដោយជម្ងឺកូវីដ-១៩ ដោយគ្រោះទឹកជំនន់ និងងាយរងសម្ពាធអតិផរណា ក៏ដូចជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវគោលនយោបាយមូលនិធិជាតិជំនួយសង្គម ជាក់ស្តែងខេត្តព្រៃវែង អនុវត្តបានដូចខាងក្រោម៖

- **ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩នៅក្នុងខេត្តព្រៃវែង៖** ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣នេះ

មានអ្នកទទួលផលសរុបចំនួន ៧៦.៧៨១គ្រួសារ សរុបទឹកប្រាក់ចំនួន ២៨០.០៩៥លានរៀល(**ពីររយប៉ែតសិបបីលាន កៅសិបប្រាំលានរៀល**)។

- **ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដោយសម្ពាធអតិផរណា៖** បានសម្ភាសន៍ចំនួន ៣១.៣៧៥គ្រួសារ។ គិតត្រឹមថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ មានអ្នកទទួលផលសរុប ១១.៣៦០គ្រួសារ ស្មើនឹងមនុស្ស ២១.៦៨២នាក់ ស្រី១៩.១៤៣នាក់ សរុបជាទឹកប្រាក់ចំនួន ១.៣៥៩លានរៀល(**មួយប៊ីលាន បីរយហាសិបប្រាំបួនលានរៀល**) ។
- **ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់៖** គិតត្រឹមថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣ មានអ្នកទទួលផលសរុប៣.៨៦៩គ្រួសារ ស្មើនឹងមនុស្ស១២.៥៤២នាក់ ក្នុងនោះមានកុមារអាយុក្រោម៥ឆ្នាំ ១.៣៥៥នាក់ មនុស្សវ័យចាស់ ២.៤៣៣នាក់ ជនមានពិការភាព ៣៣៩នាក់ សរុបជាទឹកប្រាក់ដែលបានបើកផ្តល់ចំនួន ៥៧៦លានរៀល។
- **ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្រ្តីមានផ្ទៃពោះ និងកុមារមានអាយុក្រោម២ឆ្នាំ៖** គិតត្រឹមថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ មានអ្នកទទួលផលសរុបចំនួន ១០.៣១១នាក់ (ស្រ្តី ៧.២៨០នាក់ និងកុមារ ៣.០៣១នាក់) សរុបជាទឹកប្រាក់ចំនួន ៤.៥០២លានរៀល(**បួនប៊ីលាន ប្រាំរយពីរលានរៀល**)។

### គ- កំណើនសេដ្ឋកិច្ចនៅក្នុងខេត្តព្រៃវែង

ក្នុងរយៈ៥ឆ្នាំកន្លងមកនេះ បច្ចុប្បន្នខេត្តមានផលិតផលក្នុងស្រុកសរុប ចំនួន**១.៧៣៨លានដុល្លា** បើប្រៀបធៀបទៅនឹង៥ឆ្នាំមុន (មុនឆ្នាំ២០១៨) ផលិតផលក្នុងស្រុកសរុបមានចំនួន**១.២៧៨លានដុល្លា** មានការកើនឡើងចំនួន**៤៦០លានដុល្លា** ស្មើនឹង**៣៦**%។ ក្នុងរយៈពេល ៥ឆ្នាំនេះ GDP សម្រាប់ប្រជាពលរដ្ឋម្នាក់ៗ មានចំនួន ១.៣០៣,៥ដុល្លា ស្ថិតនៅលំដាប់**លេខ១៩** ក្នុងចំណោម២៤ខេត្ត(មិនរាប់បញ្ចូលរាជធានីភ្នំពេញ) បើប្រៀបធៀបទៅនឹង៥ឆ្នាំមុន (មុនឆ្នាំ២០១៨) GDP ប្រជាពលរដ្ឋម្នាក់ៗមានចំនួន ១.១៣៧,៩ដុល្លា ស្ថិតនៅលំដាប់**លេខ២១** ក្នុងចំណោម២៤ខេត្ត។

### ឃ-ការវិនិយោគសាធារណៈ និងឯកជន

**១.ការវិនិយោគសាធារណៈ**

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** តែងយកចិត្តទុកដាក់ខ្ពស់ទៅលើ មន្ត្រីរាជការ និងប្រជាពលរដ្ឋទូទាំងប្រទេស ជាពិសេសខេត្តព្រៃវែងយើងទទួលបាននូវការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ក្នុងការផ្តល់ទុនវិនិយោគ ហេដ្ឋារចនាសម្ព័នសាធារណៈក្នុងរយៈពេលប្រាំឆ្នាំ គិតជាទឹកប្រាក់ **ចំនួន ១.១១៥.៤៧៣(មួយទ្រីលានមួយរយដប់ប្រាំប៊ីលានបួនរយចិតសិបបីលានរៀល)** ទៅលើវិស័យដូចខាងក្រោម៖

- ហេដ្ឋារចនាសម្ព័ន្ធរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់៖ សាងសង់អាគារសាលាខេត្តថ្មី ៧ខ្នង អគារច្រកចេញចូលតែមួយខេត្ត ក្រុង ស្រុក៦ខ្នង អាគាររដ្ឋបាលសាលាស្រុក១ខ្នង និងអាគារសាលប្រជុំសាលាស្រុក១ខ្នង អាគារសាលាឃុំ៥២ខ្នង និងសួនច្បារ**សម្តេចអគ្គធម្មពោធិសាល ជា ស៊ីម**១កន្លែង និងសួនច្បារ**សម្តេចក្រឡាហោម ស ខេង** ១កន្លែង ចំណាយថវិកា**៧៥.៤២៣លានរៀល** (**ចិតសិបប្រាំប៊ីលាន បួនរយម្ភៃបីលានរៀល**)។
- វិស័យសុខាភិបាល៖ ការសាងសង់អគារមន្ទីរពេទ្យ ០១កន្លែង មណ្ឌលសុខភាព ៩កន្លែង ប៉ុស្តិ៍សុខភាព ០២កន្លែង អគាររដ្ឋបាលមន្ទីរសុខាភិបាល ០១ខ្នង អគារការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ០១ខ្នង និងសំណង់មួយចំនួនទៀត សរុបជាថវិកា **១២.០៩៤លានរៀល**(**ដប់ពីរប៊ីលាន កៅសិបបួនលានរៀល**)

- វិស័យអប់រំ៖ ការសាងសង់អគារសិក្សា ១៤៩ខ្នង ស្មើនឹង ៧៧២បន្ទប់ ស្មើនឹង**ថវិកា ៣៧.០៤០លានរៀល** (**សាបសិបប្រាំពីរប៊ីលាន សែសិបលានរៀល**)
- វិស័យសាធារណការ និងអភិវឌ្ឍន៍ជនបទ៖ ស្ថាបនាផ្លូវក្រាលកៅស៊ូប្រវែង ២២៨,៧៧គ.ម ផ្លូវបេតុងប្រវែង ២៣,៥១ គ.ម ផ្លូវដីល្បាយថ្ម ក្រាលគ្រួសក្រហម និងខ្សាច់ភ្នំប្រវែង ៤៧១,៩៨គ.ម ស្ពាន២០កន្លែងប្រវែង ៥៩៤ម៉ែត្រ លូមូលបណ្ដោយផ្លូវប្រវែង ៥,៣៦គ.ម មានទំហំថវិកា**៥៥០.៥៥៦លានរៀល**(**ប្រាំរយហាសិបប៊ីលាន ប្រាំរយហាសិបប្រាំមួយលានរៀល**)
- វិស័យកសិកម្ម និងធនធានទឹក៖ បានសាងសង់ ជួសជុល ថែទាំ និងស្តារប្រព័ន្ធធារាសាស្ត្រ ប្រវែង ២១២,៦២គ.ម និងសាងសង់មជ្ឈមណ្ឌលផលិតកម្មពូជ និងឃ្លាំងសម្ងួតស្រូវ ចំណាយថវិកាសរុប **៤៧៧.៤០០លានរៀល**(**បួនរយចិតសិបប្រាំពីរប៊ីលាន បួនរយលានរៀល**)។

**២.ការវិនិយោគឯកជន**

ក្រោមដំបូលសុខសន្តិភាពដែលធ្វើអោយប្រទេសជាតិមានការអភិវឌ្ឍរីកចម្រើនជាបន្តបន្ទាប់ បានជំរុញអោយអ្នកវិនិយោគជាតិ និងអន្តរជាតិមកបណ្ដាក់ទុនក្នុងប្រទេសកម្ពុជា។ ក្នុងនោះខេត្តព្រៃវែងក៏មានការវិវត្តន៍រីកចម្រើនប្រែប្រួលគួរអោយកត់សម្គាល់ ជាក់ស្តែងក្នុងរយៈ៥ឆ្នាំនេះ មានអ្នកវិនិយោគឯកជន លើវិស័យអចលនទ្រព្យ និងសេវាកម្មផ្សេងៗមានទំហំទឹក**ប្រាក់១៩៥,៧៥លានដុល្លា**(មិនរាប់បញ្ចូលវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ)ក្នុងនោះ៖

- សេវាសុខាភិបាលឯកជន រួមមានមន្ទីរសម្រាកព្យាបាល និងសម្ភព បន្ទប់សម្រាកព្យាបាល ឱសថស្ថានសរុបចំនួន ១.០៤៩ទីតាំង មានទំហំថវិកាសរុប ២៣,២៩លានដុល្លា។
- វិស័យសំណង់ និងអចលនទ្រព្យ(មានដូចជាដី ផ្សារ ផ្ទះលំហែ ...)៖ ខេត្តមានក្រុមហ៊ុនវិនិយោគចំនួន១៧ក្រុមហ៊ុន លើផ្ទៃដីទំហំ ១៤០ហិកតា មានទំហំទឹកប្រាក់ ១៤១លានដុល្លា។
- ស្ថានីយប្រេងឥន្ទនៈ និងឧស្ម័នសាងសង់ថ្មី ចំនួន ៨៧ស្ថានីយ មានទំហំថវិកាប្រមាណ ៧លានដុល្លា
- កសិកម្ម៖ កសិដ្ឋានចិញ្ចឹមសត្វគោ ក្របី និងបក្សី ៨៨កន្លែង ថវិកា៦២៥.០០០ដុល្លា
- ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសរុបចំនួន ២២គ្រឹះស្ថាន ក្នុងនោះធនាគារពាណិជ្ជចំនួន១១គ្រឹះស្ថានស្មើនឹង៦២សាខា និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន១១គ្រឹះស្ថាន ស្មើនឹង១៣សាខា ។
- រោងចក្រ សហគ្រាស៖ រោងចក្រចំនួន០៣មូលដ្ឋាន មានកម្មករ ៣.៥៤១នាក់ ទុនវិនិយោគ ៤,៩២លានដុល្លា, សហគ្រាសធុនតូច-មធ្យមចំនួន ៤២មូលដ្ឋាន មានកម្មករ ៣.៨៧៨នាក់ ទុនវិនិយោគ ៩,៩២លានដុល្លា, សិប្បកម្មកើនឡើង១៤៤មូលដ្ឋាន មានកម្មករ៤៣២នាក់ ទុនវិនិយោគ១,៤៥លានដុល្លា និងវិស័យទឹកស្អាតកើនឡើង១១មូលដ្ឋាន មានកម្មករ ១៣៤នាក់ ទុនវិនិយោគ ៧,៥៤លានដុល្លា។

**ខ-ការផ្តល់សេវាសាធារណៈ**

- យន្តការសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋមាន ០៣ថ្នាក់ ក្នុងគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព និងគណនេយ្យភាព នៃការផ្តល់សេវារដ្ឋបាលលើវិស័យនានានៅកន្លែងតែមួយ។ ផ្អែកតាមស្មារតីនេះរដ្ឋបាលខេត្ត បានរៀបចំអគារអង្គភាពច្រកចេញ-ចូលតែមួយខេត្ត ដែលផ្តល់សេវាលើ ១៤វិស័យ ការិយាល័យច្រកចេញចូលតែមួយ ១៣ក្រុង-ស្រុក ផ្តល់សេវាលើ ១៣វិស័យ និងបានដាក់ឱ្យដំណើរការយន្តការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ នៅតាមសាលាឃុំ-សង្កាត់ទាំង ១១៦ នៅក្នុងខេត្តតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។ ការផ្តល់សេវាតាមយន្តការច្រកចេញ-ចូលតែមួយ ត្រូវបាន

ទទួលការគាំទ្រ និងសាទរពីប្រជាពលរដ្ឋ ដែលជាអ្នកស្នើសុំសេវា ដោយរាជរដ្ឋាភិបាលបានបង្វិតសេវាឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ និងនីតិវិធីមានលក្ខណៈសាមញ្ញ តម្លាភាព គណនេយ្យភាព ភាពជឿជាក់ទុកចិត្តបាន និងគ្មានអំពើពុករលួយ។

- ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋតាមរយៈយន្តការច្រកចេញចូលតែមួយក្នុងខេត្តសរុបចំនួន**៨៦.៦៤៣សេវា** និងទទួលបានចំណូលសរុប**២,០២លានដុល្លា**។
- ការអនុវត្តនូវគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក សម្រេចបាន**ចំនួន៨៩៧គម្រោង** ថវិកាចំណាយលើគម្រោងវិនិយោគសរុបចំនួន**៣២,២០លានដុល្លា ក្នុងនោះសាងសង់ផ្លូវដីសប្រវែង ៥៣៩ គីឡូម៉ែត្រ ជួសជុលផ្លូវក្រាលខ្សាច់ក្រហមប្រវែង ១.៧៩០ គីឡូម៉ែត្រ ក្រាលគ្រួសក្រហម ២៧៥ គីឡូម៉ែត្រ** ជួសជុលទំនប់ ១២ គីឡូម៉ែត្រ សាងសង់ផ្លូវបេតុង ១០២ គីឡូម៉ែត្រ សាងសង់លូរំដោះទឹក ៣.៥០០ ម៉ែត្រ និងស្តារប្រឡាយប្រវែង ៦៧៥គីឡូម៉ែត្រ ។

## ច-ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ និងការងារគ្រប់គ្រងច្រកទ្វារព្រំដែន

- ខេត្តព្រៃវែង មានព្រំប្រទល់រដ្ឋបាលជាប់នឹងខេត្តចំនួន០៣ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម គឺខេត្តតៃនិញ ខេត្តឡុងអាន និងខេត្តដុងថាប់ ។
- មានច្រកទ្វារព្រំដែន ឆ្លងកាត់ចំនួន០៦ គឺច្រកទ្វារព្រំដែនអន្តរជាតិបន្ទាយចក្រី កោះរកា ម៉ឺនជ័យ ច្រកទ្វារព្រំដែនទ្វេភាគីកោះសំពៅ និងច្រកទ្វារតំបន់ព្រំដែនពាមមន្ទារ ស្វាយអាង៉ោង។
- ចំពោះកិច្ចសហប្រតិបត្តិការទៅវិញទៅមករវាងអាជ្ញាធរ និងសមត្ថកិច្ចទាំងសងខាង ខេត្តបានយកចិត្តទុកដាក់ក្នុងការបង្កើនទំនាក់ទំនង និងកិច្ចសហការល្អ ក្នុងគោលដៅពង្រឹងការងារសន្តិសុខ សេដ្ឋកិច្ច ការប្រកបរបរអាជីវកម្ម របស់ប្រជាពលរដ្ឋ និងការងារអភិវឌ្ឍព្រំដែនមិត្តភាព សន្តិភាពបានល្អប្រសើរ។

## ឆ-លទ្ធផលការងារតាមវិស័យសំខាន់ៗ

### ១- ការងារប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ

- ចំណូលពន្ធ អាករ និងកម្រៃផ្សេងៗ ដែលប្រមូលបានពីការបង់ពន្ធ និងការបង្ក្រាបទំនិញគេចវេសពន្ធ ក្នុងខេត្តសរុបចំនួន **១៧,៧៤លានដុល្លា** ក្នុងនោះចំណូលពន្ធគយចល័តក្នុងខេត្តចំនួន១,៨៨លានដុល្លា និងចំណូលពន្ធគយពីច្រកទ្វារព្រំដែនចំនួន១៥,៨៦លានដុល្លា។ **ដោយឡែកចំណូលពន្ធក្នុងឆ្នាំ២០២២ចំនួន ៤,៨២លានដុល្លា, ចំណូលក្នុងមួយខែប្រមូលបានជាមធ្យមចំនួន ០,៣១លានដុល្លា។**
- ចំណូលពន្ធដារក្នុងខេត្តសរុប **២៩,៦៩លានដុល្លា** ក្នុងនោះចំណូលថវិកាថ្នាក់ជាតិចំនួន១៣លានដុល្លា និងចំណូលថវិកាថ្នាក់ក្រោមជាតិចំនួន ១៦,៦៩លានរៀល
- ខេត្តព្រៃវែង មានទីតាំងសម្រាប់កែច្នៃថ្មសំណង់គ្រប់ប្រភេទ និងមានទន្លេមេគង្គឆ្លងកាត់សម្រាប់យកធនធានខ្សាច់ចាក់លុប និងសំណង់ ជាក់ស្តែងក្នុងរយៈពេល៥ឆ្នាំ បានប្រមូលចំណូលសរុបចំនួន **៤,៥៧ លានដុល្លា** ដោយឡែកក្នុងឆ្នាំ២០២២ ប្រមូលបានចំនួន ២,១៩លានដុល្លា។

### ២- វិស័យកសិកម្ម និងធនធានទឹក

ខេត្តព្រៃវែងជាខេត្តជាប់លេខ១ ចំនួន ៣ឆ្នាំជាប់គ្នា លើការផលិតស្រូវ ។ ខេត្តមានផ្ទៃដីដាំដុះសរុបចំនួន ៣៣៧.០០០ហិកតា ក្នុងនោះផ្ទៃដីដាំដុះស្រូវវស្សាចំនួន២៥០.០០០ហិកតា ផ្ទៃដីដាំដុះស្រូវប្រាំងចំនួន៧៥.០០០ ហិកតា និងផ្ទៃដីដាំដុះដំណាំរួមផ្សំផ្សេងៗចំនួន១២.០០០ហិកតា។

ក្នុងរយៈកាល៥ឆ្នាំកន្លងមកនេះ លើវិស័យកសិកម្មដែលមានការរីកចម្រើនគួរឲ្យកត់សម្គាល់ រួមមាន៖

- **ការងារផលិតកម្មដំណាំស្រូវ៖** ខេត្តផលិតបានបរិមាណផលស្រូវសរុបចំនួនជាង ៧លានតោន (ជាមធ្យមជាង១លានតោនក្នុងមួយឆ្នាំ) បរិមាណស្រូវដែលនៅសល់ពីការប្រើប្រាស់ក្នុងខេត្តសរុបចំនួនជាង ៥លានតោន សម្រាប់នាំចេញ(ក្នុង និងក្រៅប្រទេស) គិតជាថវិកាប្រមាណ **១.២៥០លានដុល្លា**។ លើសពីនេះទៅទៀតខេត្តព្រៃវែងជាមាត់ច្រកសម្រាប់នាំចេញស្រូវ និងផ្លែស្វាយ ទៅប្រទេសជិតខាងកម្ពុជា ក្នុងនោះ
    - បាននាំចេញស្រូវសរុបចំនួន ១.២២១.៩៨៨តោន ទទួលបានចំណូលសរុប ៣១១,៦០លានដុល្លា
    - បាននាំចេញផ្លែស្វាយសរុបចំនួន ៩៣.៣០០តោន ទទួលបានចំណូលសរុប ១៩,៥៩លានដុល្លា
- **លើការងារផលិតកម្មដំណាំរួមផ្សំ៖** ក្នុងរយៈពេល៥ឆ្នាំ ខេត្តបានបង្កើតឲ្យមានសហគមន៍ផលិតបន្លែ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងខេត្ត ក្រៅខេត្ត និងរាជធានីភ្នំពេញ ដែលផលិតបន្លែបានសម្រាប់លក់ទៅកាន់ទីផ្សារប្រមាណជាង ៣ម៉ឺនតោន គិតជាមធ្យម ១៥ទៅ២០តោន ក្នុង១ថ្ងៃ។
- **ការងារផលិតកម្មសត្វ៖** នៅក្នុងខេត្តព្រៃវែងមានការចិញ្ចឹមគោ-ក្របី ៣៥១.២២៨ក្បាល ជ្រូក២៩.២០២ក្បាល និងសត្វបក្សី ៣.៣៤១.០១៣ក្បាល អ្វីដែលលេចធ្លោគួរឲ្យចាប់អារម្មណ៍នោះ គឺការចិញ្ចឹមសត្វទាយកស៊ុត។ បើតាមស្ថិតិនៅក្នុងឆ្នាំ២០២២នេះ មានទាចំនួន១.៥០២.៦៧៨ក្បាល ដែលផលិតស៊ុតទាបានចំនួន ៩៧៦.៧៤០គ្រាប់ក្នុង១ថ្ងៃ សម្រាប់ផ្គត់ផ្គង់ក្នុងខេត្ត រាជធានីភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួនទៀត។
- **ការងារជលផល** បរិមាណផលត្រីទទួលបានសរុប១៨៥.៩១០តោន ក្នុងនោះផលពីការនេសាទទឹកសាប មានចំនួន១០៥.២៣០តោន និងផលពីវារីវប្បកម្មមានចំនួន៨០.៦៨០តោន។

ខេត្តព្រៃវែងមានប្រព័ន្ធធារាសាស្ត្រសរុបចំនួន ១៧៧កន្លែង មានខ្នាតធំ៤កន្លែង មធ្យម១១កន្លែង និងខ្នាតតូច៦២កន្លែង។ អាចផ្គត់ផ្គង់ទឹកស្រោចស្រពលើផ្ទៃដីស្រែ សរុបចំនួន១៣៧.៣៣៤ហ.ត។

**៣-វិស័យសាធារណៈការដឹកជញ្ជូន និងអភិវឌ្ឍន៍ជនបទ**

- ខេត្តមានផ្លូវជាតិចំនួន **៦ខ្សែ** ប្រវែង២១៤,២៤គីឡូម៉ែត្រ និងមានផ្លូវខេត្ត ចំនួន៣៧ខ្សែ មានប្រវែង ៦៣៨,១៨គីឡូម៉ែត្រ មានស្ពានបេតុង ចំនួន១២៩កន្លែង ប្រវែង៦.៦១៣ម៉ែត្រ ស្ពានបេឡេត៍ ចំនួន០២កន្លែង ប្រវែង១១៧ម៉ែត្រ ស្ពានខ្សែកាប ចំនួន០១កន្លែង ប្រវែង២.២១៥ម៉ែត្រ ។
- បានចុះបញ្ជីយានយន្ត ៥១.៩៥៤គ្រឿង, ត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ១៨.៦២១គ្រឿង, ផ្តល់អាជ្ញាប័ណ្ណយានយន្តធ្វើអាជីវកម្មដឹកជញ្ជូន ៥.៣៤៨គ្រឿង, ផ្តល់ប័ណ្ណបើកបរ ២៥.៦៤៩ប័ណ្ណ និងចុះបញ្ជីយានដ្ឋានជួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត ៥០កន្លែង។

ចំពោះស្ថានភាពផ្លូវជនបទក្នុងខេត្តព្រៃវែង ដែលជាសសៃឈាមសេដ្ឋកិច្ចដ៏សំខាន់បានតភ្ជាប់ពីក្រុង/ស្រុក ទៅកាន់បណ្តាឃុំ/សង្កាត់ **មានសរុបចំនួន១.០៩៧ខ្សែ ប្រវែង ៣.៥៧០គ.ម** ។

ចំពោះការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ បច្ចុប្បន្ននេះ អណ្តូងគ្រប់ប្រភេទដែលបានសាងសង់មានចំនួនសរុប ១៩៨.៩៧៨ អណ្តូង មានអត្រាគ្របដណ្តប់ប្រជាពលរដ្ឋមានទឹកស្អាតកំរិតមូលដ្ឋានស្មើនឹង៩២% និងបានសាងសង់បង្គន់អនាម័យចំនួន ២២៨.៦៥៤បង្គន់ មានអត្រាគ្របដណ្តប់អ្នកប្រើប្រាស់បង្គន់អនាម័យស្មើនឹង១០០% នៃចំនួនខ្នងផ្ទះសរុប២៥៣.៣៤៤ខ្នងផ្ទះ និងខេត្តព្រៃវែងជាខេត្តទី២ បានបញ្ចប់ការបន្ទោរបង់ពាសវាលពាសកាល ODF (Open Defecation Free) នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២ ។

**៤-វិស័យរ៉ែ ថាមពល និងឧស្សាហកម្ម សិប្បកម្ម**

- បច្ចុប្បន្ន ខេត្តមានថាមពលអគ្គិសនីប្រើប្រាស់ ២៤ម៉ោង លើ២៤ម៉ោង គ្របដណ្តប់គ្រប់ក្រុង/ស្រុក និងប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់ចំនួន ២២៨.៧៨២ខ្នងផ្ទះ ស្មើនឹង ៩០,៣%នៃខ្នងផ្ទះសរុប ។
- **លើវិស័យធនធានរ៉ែ** ខេត្តមានក្រុមហ៊ុន សហគ្រាសធ្វើអាជីវកម្មរួមមាន៖ រ៉ែថ្មសំណង់ ០៦ក្រុមហ៊ុន រ៉ែខ្សាច់ភ្នំ ០៦ក្រុមហ៊ុន រ៉ែខ្សាច់សំណង់ និងដីល្បាយខ្សាច់ ០៥ក្រុមហ៊ុន (នាំចេញទៅក្រៅប្រទេស០២ក្រុមហ៊ុន) និងអាជីវកម្មជីកដី ៤៤អាជីវករ ។
- ស្ថានីយ៍ប្រេងឥន្ធនៈ និងឧស្ម័ន មានចំនួន ៣៤៤ស្ថានីយ៍។
- មូលដ្ឋានរោងចក្រ សហគ្រាសធុនតូច-មធ្យម និងសិប្បកម្ម កំពុងដំណើរការមានច្បាប់**ចំនួន ៤៩៧មូលដ្ឋាន**
- ចំពោះការងារទឹកស្អាត ទូទាំងខេត្ត មានបណ្តាញទឹកស្អាតគ្របដណ្តប់តំបន់ទីប្រជុំជនទាំង១៣ក្រុង/ស្រុក ចំនួន២៥មូលដ្ឋាន ស្មើនឹង៥៤ឃុំ/សង្កាត់(៤៣៤ភូមិ) ដែលមានប្រជាពលរដ្ឋប្រើប្រាស់៦៤ឃុំ ៣៥៧ភូមិ ស្មើនឹង៣៣.៣៤៣គ្រួសារ ដាក់បណ្តាញមេបាន ១.២៥៥គីឡូម៉ែត្រ) បរិមាណទឹកផលិតបាន ៥.២១៧.៩៧២ម$^{៣}$។

**៥-វិស័យពាណិជ្ជកម្ម**

- ក្នុងឆ្នាំ២០១៨-២០២២ ខេត្តបានធ្វើការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម រួមមាន៖ ក្រុមហ៊ុនមានចំនួន ១៥៧ក្រុមហ៊ុន សាខាក្រុមហ៊ុនចំនួន ១៧៧សាខា សហគ្រាសឯកបុគ្គល ចំនួន ១១១សហគ្រាស

**៦-វិស័យទេសចរណ៍ និងបរិស្ថាន**

- ខេត្តព្រៃវែង មានរមណីយដ្ឋានប្រវត្តិសាស្ត្រ ចំនួន **១កន្លែង** គឺរមណីយដ្ឋានប្រវត្តិសាស្ត្រនគរភ្នំ ស្ថិតក្នុងស្រុកបាភ្នំ។
- រមណីយដ្ឋានធម្មជាតិចំនួន **៣កន្លែង** គឺរមណីយដ្ឋានទួលពន្ធ័តាឡីបឹងស្នេហ៍"ដែលមានសត្វស្លាប ជាច្រើនប្រភេទ ពី១៥ម៉ឺនទៅ២០ម៉ឺនក្បាល កំពុងរស់នៅ, រមណីយដ្ឋានស្ទឹងចារ (ស្រុកកំចាយមារ) និងរមណីយដ្ឋានដីដុះ (ស្រុកពាមជរ)។
- រមណីយដ្ឋានវប្បធម៌ចំនួន **៣កន្លែង** គឺរមណីយដ្ឋានទួលបារាយអណ្តែត, រមណីយដ្ឋានទួលអស់លោកប្រធាតុ (ក្រុងព្រៃវែង) និងរមណីយដ្ឋានប្រាសាទព្រៃដើមស្រុក (ស្រុកស៊ីធរកណ្តាល) ។

- ក្នុងរយៈពេល៥ឆ្នាំនេះ ស្ថិតិភ្ញៀវទេសចរសរុបមានសរុបចំនួន១.៩២០.៣៤៤នាក់ ក្នុងនោះ៖ភ្ញៀវទេសចរជាតិចំនួន១.៩០៥.៧៦៥នាក់ ភ្ញៀវទេសចរអន្តរជាតិ សរុបចំនួន ១៤.៥៧៩នាក់
- ក្រោយពីរដ្ឋបាលខេត្ត បានសហការជាមួយអន្តរក្រសួង ដែលដឹកនាំដោយក្រសួងបរិស្ថាន បានបង្កើតតំបន់ប្រើប្រាស់ច្រើនយ៉ាងទួលព័ន្ធតាឡី បឹងស្នេហ៍ ដែលមានទំហំ៣.៥៥៧ហិកតា តាមរយៈអនុក្រឹត្យលេខ១៦ អនក្រ.បក របស់រាជរដ្ឋាភិបាល។ រដ្ឋបាលខេត្តបានកែលម្អ ផ្សព្វផ្សាយដើម្បីទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ចូលទស្សនាបានច្រើនកុះករ ដែលមានសត្វបក្សីប្រមាណ ៤៩ប្រភេទ ប្រមាណ ១៥ម៉ឺនទៅ២០ម៉ឺនក្បាល។

* **សូមបញ្ជាក់ថាតំបន់ប្រើប្រាស់ច្រើនយ៉ាងបឹងស្នេហ៍ ដែលមានផ្ទៃបឹង ទំហំ៣.៥៥៧ហិកតា ជាប្រភពទឹកដ៏សំខាន់ពុំចេះរីងស្ងួត គ្រប់រដូវ និងមានភាពទាក់ទាញយ៉ាងខ្លាំងដល់ការវិនិយោគផ្នែកវិស័យទេសចរណ៍ ដោយមានបណ្តាក្រុមហ៊ុនមួយចំនួនកំពុងសិក្សា ដើម្បីបង្កើតជាតំបន់ទេសចរណ៍ធម្មជាតិ ដែលរដ្ឋបាលខេត្តកំពុងពិនិត្យ សិក្សាលើគម្រោងទាំងនោះ។**

- រដ្ឋបាលខេត្ត បានសហការជាមួយអន្តរក្រសួង ដែលដឹកនាំដោយក្រសួងបរិស្ថាន ដើម្បីដាក់បញ្ចូល រៀបចំ បង្កើតជាតំបន់បេតិកភណ្ឌធម្មជាតិ និងវប្បធម៌ប្រវត្តិ សាស្ត្រ នគរភ្នំ ឈើកាច់បាភ្នំ ជាតំបន់ការពារដោយ អនុក្រឹត្យ។
- ខេត្តបានរៀបចំទីតាំងទីលានចាក់សំរាមចំនួន ១០ទីតាំង មានចំនួន០៥ក្រុមហ៊ុន ដែលបានកំពុងអនុវត្ត និងដំណើរការ។

**៧-ការងាររៀបចំដែនដី នគរូបនីយកម្ម និងសំណង់:**

- ចាប់ពីអនុវត្តការងារឆ្នាំ២០០៣ ដល់ឆ្នាំ២០២២ បានចេញប័ណ្ណជូនប្រជាពលរដ្ឋសរុបចំនួន ៦៦៩.៣៦៨ប័ណ្ណ មាន២៤៧.៩១៤គ្រួសារ ស្មើនឹង ៨៥%នៃគ្រួសារសរុប ២៩២.៩៣៥ ដែលអនុវត្តរួចលើក្រុង/ស្រុក ចំនួន១៣ និងឃុំ/សង្កាត់ចំនួន១០០ ស្មើនឹង ៨៧៤ភូមិ ។
- ដោយឡែកក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) បានចេញប័ណ្ណរួចចំនួន១៧៥.៥៥៤ប័ណ្ណ មានគ្រួសារ ចំនួន ៤៣.៨៨៩គ្រួសារ។

**៨-វិស័យសុខាភិបាល**

- ខេត្តមានមន្ទីរពេទ្យបង្អែកខេត្តចំនួន ១កន្លែង, មន្ទីរពេទ្យបង្អែកស្រុកចំនួន ១១កន្លែង, មណ្ឌលសុខភាព ១១៣កន្លែង ប៉ុស្តិ៍សុខភាព ៧កន្លែង សេវាសុខាភិបាលឯកជនចំនួន ១.០៤៩ទីតាំង និងអាគារផលិតអុកស៊ីសែន ០១ខ្នង ដែលជាអំណោយដ៏ថ្លៃថ្លារបស់ ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** សម្រាប់ផ្គត់ផ្គង់ចំនួន ៣ខេត្ត គឺខេត្តព្រៃវែង ស្វាយរៀង និងត្បូងឃ្មុំ។
- បានពិនិត្យ ពិគ្រោះ ព្យាបាលជំងឺសរុបចំនួន ៩៧៣.១៧៧ករណី សម្រាកព្យាបាល ៣៤.០៣១ករណី ។

**៩-វិស័យអប់រំ យុវជន និងកីឡា**

- ទូទាំងខេត្តមាន សាលាមត្តេយ្យចំនួន ៧០៨កន្លែង សាលាបឋមសិក្សា៥៤៧កន្លែង អនុវិទ្យាល័យ៩៣ កន្លែង វិទ្យាល័យ៣៣កន្លែង វិទ្យាស្ថាន២កន្លែង សាកលវិទ្យាល័យ២កន្លែង សាលាបណ្តុះបណ្តាលចំនួន២ កន្លែង មជ្ឈមណ្ឌលសិក្សាសហគមន៍ មាន១៤កន្លែង។
- អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** មានចំនួន ១១ ខ្នង ស្មើនឹង ៦៣បន្ទប់។
- អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានចំនួន ៣០០ខ្នង ស្មើនឹង ១.៨៧៩បន្ទប់។
- អាគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ចំនួន ១០១ខ្នង ស្មើនឹង ៥២៩បន្ទប់។
- ក្នុងឆ្នាំសិក្សារយៈពេល៥ឆ្នាំ(២០១៨-២០២២)កន្លងមកនេះ ៖ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ខេត្តព្រៃវែង មានសិស្សប្រឡងសរុប **ចំនួន៣៣.៩៧៣នាក់** សិស្សប្រឡងជាប់សរុប**ចំនួន២៧.៦៩២នាក់** ស្មើនឹង ៨៤,៥៥% ក្នុងនោះ៖ និទ្ទេសA ចំនួន១៨៥នាក់ និទ្ទេសBចំនួន១.២៦៣នាក់ និទ្ទេសCចំនួន១.៧៥៥ នាក់ និទ្ទេសDចំនួន៥.៨៤៩នាក់ និង និទ្ទេសEចំនួន១០.៣០១នាក់ ។

**១០-វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- វិស័យកាត់ដេរចំនួន ០៩សហគ្រាស មានកម្មករ និយោជិតសរុប ៣.៣៣៨នាក់ ស្រី ២.៩៤៣នាក់

- វិស័យក្រៅពីកាត់ដេរ ចំនួន១៦២សហគ្រាស មានកម្មករ-និយោជិតសរុប៤.១០៥នាក់ ស្រី១.៣៦៩នាក់
- ខេត្តមានវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ១កន្លែង បានបើកវគ្គបណ្តុះបណ្តាល ចំនួន២៧០វគ្គ មានសិក្ខាកាម ចំនួន៨.៤៦១នាក់ ស្រី៣.៦៤២នាក់ រួមមាន២៩ជំនាញ ដូចជា៖ ជំនាញគណនេយ្យ, ជំនាញអគ្គិសនី សេវាកម្មកុំព្យូទ័រ, ការដំឡើងបណ្តាញអគ្គិសនីក្នុងអគារ, ការងារកំបោរ, ការថែទាំនិងជួសជុលរថយន្ត, ការដំឡើងសសៃដែក....។

**១១-ការងារសង្គមកិច្ច និងអតីតយុទ្ធជន**

- ជនមានពិការភាពក្រីក្រតាមសហគមន៍ក្នុងខេត្ត បានប្រកាសទទួលស្គាល់ និងផ្តល់ប័ណ្ណសង្គមកិច្ច ហើយទទួលបានរបបឧបត្ថម្ភគោលនយោបាយ ចំនួន **២.៦១៦នាក់**
- ជនមានពិការភាពដែលកំណត់អត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋានដើម្បីទទួលបានអត្តសញ្ញាណប័ណ្ណពិការភាព ចំនួន **២២.៨៨០នាក់**
- សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាទទួលមរណភាពនិងបានទទួលថវិកាបេឡាមរណសង្គ្រោះចំនួន**១០៦នាក់**
- ខេត្តបានបញ្ជូនសមាជិកអតីតយុទ្ធជន ចំនួន **៥៤គ្រួសារ** ដែលបានស្ម័គ្រចិត្តទៅរស់នៅលើដីសម្បទានសង្គមកិច្ចខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។
- **គ្រួសារក្រីក្រជុំទី១៤ និងគ្រួសារក្រីក្រតាមការស្នើសុំក្នុងខេត្តសរុបចំនួន ៥១.៣៨៤គ្រួសារ ក្នុងនោះគ្រួសារក្រីក្រកម្រិត១ ចំនួន ១៨.៦២១គ្រួសារ និងគ្រួសារក្រីក្រកម្រិត២ ចំនួន ៣២.៨៦៣គ្រួសារ។**

**១២-ការងារធម្មការ និងសាសនា**

- ខេត្តព្រៃវែង មានវត្តអារាមសម្រាប់ប្រជាពលរដ្ឋគោរពប្រតិបត្តិតាមប្រពៃណីសាសនា សរុបចំនួន ៥១៩វត្ត ក្នុងនោះវត្តធម្មយុត្តិ ចំនួន ១៩វត្ត និងព្រះសង្ឃសរុប ៤.១៥៩អង្គ គណៈធម្មយុត្តិ ៧៧អង្គ។
- មានវិហារ និងស្នាក់ការពាហិរសាសនាចំនួន ៩១កន្លែង ក្នុងនោះ សាសនាគ្រិស្ទ ៧៣កន្លែង ឥស្លាម៦កន្លែង មហាយាន៨កន្លែង អ្នកតាចិន៣កន្លែង និងព្រហ្មញ្ញសាសនា ១កន្លែង។

**១៣-ការងារដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

- ដើម្បីធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋលើបញ្ហាដីធ្លី ការលើកកម្ពស់កម្រិតជីវភាពរស់នៅ ការកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ និងភាពសុខដុមនៃសង្គម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ រដ្ឋបាលខេត្ត តែងបានខិតខំយកចិត្តទុកដាក់ដោះស្រាយវិវាទជូនប្រជាពលរដ្ឋ តាមរយៈការប្រើយន្តការពីរបែបៈគឺ គណៈកម្មការរដ្ឋបាល និងគណៈកម្មការសុរិយោដី ដោយឈរលើគោលការណ៍ច្បាប់ជាធរមាន មិនមានការបង្ខិតបង្ខំ គំរាមកំហែង ឬបំភិតបំភ័យភាគីណាមួយឡើយ។
- ក្នុងរយៈពេល៥ឆ្នាំមករដ្ឋបាលខេត្ត ទទួលបានពាក្យបណ្តឹងចំនួន**២៤៩**ករណី បានដោះស្រាយចប់រួចរាល់ជាស្ថាពរចំនួន**២១៣**ករណី កំពុងបន្តដោះស្រាយចំនួន**២១**ករណី និងច្រានចោលចំនួន**១៥**ករណី។

**III-ទិសដៅបន្ត**

**រដ្ឋបាលខេត្តព្រៃវែង** បានបន្តជម្រុញសកម្មភាពសំខាន់ៗ រួមមាន៖

- ខិតខំអនុវត្តកម្មវិធីនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ឲ្យទទួលបានជោគជ័យ ។

- ប្តេជ្ញារក្សាសន្តិភាព សណ្តាប់ធ្នាប់សាធារណៈ តាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព និងបទបញ្ជារបស់រាជរដ្ឋាភិបាលឲ្យមានប្រសិទ្ធភាព ។
- បន្តជម្រុញការកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ទីប្រជុំជន និងជនបទ តាមសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋមូលដ្ឋាន
- អនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង/ស្រុក និងឃុំ/សង្កាត់ឲ្យទទួលបានជោគជ័យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់មូលដ្ឋាន ។
- បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការដោះស្រាយសំណើ សំណូមពរ ក្តីកង្វល់ និងតម្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឲ្យកាន់តែមានការឆ្លើយតបបំផុត ។
- ទាក់ទាញវិនិយោគិន(ជាតិ-អន្តរជាតិ) មកវិនិយោគ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ខេត្ត ឲ្យមានសន្ទុះរីកចម្រើនបន្ថែមទៀត ។

**ជាទីបញ្ចប់** ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមបួងសួងប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ និងសូមគោរពជូនពរ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុងអង្គសន្និសីទ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សមប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរព្រះគុណ និងអរគុណ**!